**អង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍**

**ក្រុមបណ្តុះបណ្តាលដើម្បីអនាគតមានការអភិវឌ្ឍន៍**

# Trainer Team for Future Development
# 'TTFD'

## I. សេចក្តីផ្តើម

អង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ ជាអង្គការមិនមែនរដ្ឋាភិបាលដែលមិនស្វែងរកកំរៃ បង្កើតឡើងដោយអតីតនិស្សិតបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងវិទ្យាស្ថានបណ្តុះបណ្តាលមួយចំនួនទៀតនៅព្រះរាជាណាចក្រកម្ពុជា នៅខែធ្នូ ឆ្នាំ២០០៥ ។ គំនិតផ្តួចផ្តើមបង្កើតអង្គការនេះឡើង គឺមានមូលហេតុសំខាន់ៗបីដែលក្រុមស្ថាបនិកយើងបានធ្លាប់ឆ្លងកាត់ និងជួបប្រទះ

១. នៅពេលដែលស្ថាបនិក ទើបបានបញ្ចប់ការសិក្សាពីមហាវិទ្យាល័យ បានប្រឈមនឹងការលំបាកក្នុងការស្វែងរកការងារធ្វើ ដែលជាតួនាទីរបស់ពលរដ្ឋគ្រប់រូប នៅពេលបញ្ចប់ការសិក្សាហើយ ត្រូវមានទំនួលខុសត្រូវក្នុងការរកប្រាក់ចំណូលចិញ្ចឹមខ្លួន និងគ្រួសាររបស់ខ្លួន។ ទោះជានៅដំណាក់កាលនោះនៅមិនទាន់មានមហាវិទ្យាល័យឯកជន ហើយចំនួននិស្សិតនៅមានចំនួនដ៏តិចតួចនៅឡើយក៏ដោយ ក៏បញ្ហានៃការពិបាកទទួលបានការងារបានកើតឡើងចំពោះស្ថាបនិកយើងដែរ ។ ស្ថាបនិកយើងបានស្វែងយល់ និងវិភាគឃើញថា ចុះបើនាពេលបច្ចុប្បន្ននេះ មហាវិទ្យាល័យឯកជនរីកដុះដាលព្រោងព្រាតដូចផ្សិតខែវស្សា ហើយនិស្សិតរាប់ពាន់រាប់ម៉ឺននាក់ដែលបានបញ្ចប់ការសិក្សាក្នុងមួយឆ្នាំៗ តើការស្វែងរកការងារ ជួបប្រទះនឹងការប្រកួតប្រជែងក្នុងកំរិតណាទៅ? វាពិតជាពិបាក ប្រសិនបើនិស្សិតទាំងអស់មិនព្យាយាមស្វះស្វែងរកការបណ្តុះបណ្តាលជំនាញខ្លីៗបន្ថែមទៀត ដែលផ្តោតជាសំខាន់ទៅលើរបៀបរបបធ្វើការងារដែលអង្គការ/ស្ថាប័ន ប្រកាន់យកនាពេលបច្ចុប្បន្ននេះ ។

២. បន្ទាប់ពីឆ្លងកាត់បទពិសោធន៍នៅក្នុងការងារផ្នែកអភិវឌ្ឍន៍ និងអភិរក្ស ជាមួយអង្គការមិនមែនរដ្ឋាភិបាល ក៏ដូចជាតាមក្រសួងស្ថាប័នរបស់រដ្ឋមួយរយៈកាលច្រើនឆ្នាំកន្លងមក ស្ថាបនិកយើងឈ្វេងយល់ឃើញថា ប្រជាកសិករនៅតំបន់ជនបទក្រីក្រនៅតែជួបប្រទះនូវការខ្វះខាតស្បៀង ហើយជីវភាពរស់នៅ ស្ថិតនៅក្នុងភាពក្រីក្រ ដែលក្នុងនោះបញ្ហាជាសំខាន់គឺការធ្វើកសិកម្មរបស់ប្រជាពលរដ្ឋនៅទទួលបានទិន្នផលទាបដែលមិនអាចឆ្លើយតបបានទៅនឹងតំរូវការគ្រួសារ មិនតែប៉ុណ្ណោះ ការខ្វះខាតចំណេះដឹងផ្នែកបច្ចេកទេសដើម្បីបង្កើនទិន្នផលកសិកម្ម និងការប្រើប្រាស់ថ្នាំពុលកសិកម្ម

នៅតែចោទជាបញ្ហាដ៏ធ្ងន់ធ្ងរដែលនាំអោយមានផលប៉ះពាល់ដល់បរិស្ថាន។ ដោយសារបញ្ហាជីវភាពរបស់ប្រជាពលរដ្ឋក្រីក្រ និងភាពលោភលន់ហួសប្រមាណពីជនមួយចំនួន ធ្វើអោយការទាញយកផលប្រយោជន៍ពីធនធានធម្មជាតិ មានលក្ខណៈខុសប្រក្រតី ដែលអាចនឹងឈានទៅរកភាពវិនាសហិនហោចនាពេលអនាគតដ៏ខ្លី ប្រសិនបើមិនមានការយកចិត្តទុកដាក់កែប្រែស្ថានភាពបែបនេះនោះ

៣. នៅក្រោយពីបានចូលប្រលូកនៅក្នុងការងារសង្គមជាច្រើនឆ្នាំកន្លងមក ស្ថាបនិកយើងឈ្វេងយល់បានថា នាពេលបច្ចុប្បន្ននេះសង្គមកម្ពុជាបានស្ថិតនៅក្នុងដំណាក់កាលមួយដែលមានភាពច្របូកច្របល់នៅក្នុងសីលធម៌សង្គម ភាពអយុត្តិធម៌ និងពុករលួយបានកើតឡើងយ៉ាងគគ្រឹកគគ្រេង ដែលទាមទារចាំបាច់តំរូវអោយមានការបណ្តុះមនសិការរស់នៅស្អាតស្អំ មានសីលធម៌ និងយុត្តិធម៌ ទើបសង្គមកម្ពុជាយើងអាចមានការអភិវឌ្ឍន៍ជឿនលឿនទៅមុខប្រជែងជាមួយនឹងប្រទេសនានាដទៃទៀត ។

ទោះបីជានាពេលបច្ចុប្បន្ននេះ នៅទូទាំងព្រះរាជាណាចក្រកម្ពុជាមានអង្គការ ស្ថាប័នជាច្រើនបាន និងកំពុងបំពេញបេសកកម្មដើម្បីអភិវឌ្ឍន៍សង្គមកម្ពុជាយ៉ាងសកម្មយ៉ាងណាក៏ដោយ ប៉ុន្តែប្រសិនបើមានក្រុម រឺអង្គការបន្ថែមទៀតចូលរួមនៅក្នុងការងារដ៏ថ្លៃថ្លានេះ វានឹងរិតធ្វើអោយសង្គមកម្ពុជាយើងកាន់តែឆាប់មានការប្រែប្រួលឈានទៅរកការអភិវឌ្ឍន៍រីកចំរើនពិតប្រាកដ ។ ដោយឈរលើគោលការណ៍នេះ និងមនសិការដ៏មោះមុតរួមជាមួយនឹងលទ្ធភាពជាក់ស្តែងរបស់ខ្លួន អតីតនិស្សិតចំនួន ៦រូប បានរួមគ្នាបង្កើតជាអង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ នេះឡើង ដើម្បីបំពេញបេសកកម្មទៅលើវិស័យសំខាន់ៗដូចខាងក្រោម :

- ការបណ្តុះបណ្តាលពង្រឹងសមត្ថភាពនិស្សិតលើមុខជំនាញខ្លីៗទាក់ទងនឹងការអភិវឌ្ឍន៍សហគមន៍ និងអភិរក្សធនធម្មជាតិ និងបរិស្ថាន ដើម្បីផ្តល់ឱកាសងាយស្រួលក្នុងការទទួលបានការងារ ។ បន្ថែមពីលើនេះ ការបណ្តុះបណ្តាលគឺជាផ្នែកដ៏សំខាន់នៅក្នុងការបណ្តុះមនសិការនិស្សិត ក៏ដូចជាប្រជាពលរដ្ឋអោយមានភាពប្រាកដនិយម និងឧត្តមគតិជួយអភិវឌ្ឍន៍សង្គមជាតិយើង
- ការងារអភិវឌ្ឍន៍សហគមន៍ ជាពិសេសតាមការកែលំអបច្ចេកទេស ដើម្បីបង្កើនទិន្នផលផលិតកម្មកសិកម្ម, ការប្រើប្រាស់ធនធានធម្មជាតិ និងបរិស្ថានសមស្រប ប្រកបដោយនិរន្តរភាពនៅតាមសហគមន៍ ។
- បេសកកម្មផ្សព្វផ្សាយនូវភាពស្អាតស្អំ យុត្តិធម៌ និងសីលធម៌ល្អ ថ្លៃថ្នូរនៅក្នុងសង្គម ។ មិនមែនជាការប្រឆាំងនឹងជន រឺក្រុមណាមួយនោះឡើយ ប៉ុន្តែសកម្មភាពរបស់អង្គការ គឺព្យាយាមបញ្ចុះបញ្ចូលបណ្តុះនូវផ្នត់គំនិតថ្មី មនសិការជឿជាក់ដល់ប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានក្នុងស្មារតីទទួលខុសត្រូវខ្ពស់ដើម្បីរួមគ្នាជួយសង្គមជាតិអោយមានភាពរីកចំរើន ។

## II. ប្រវត្តិបេសកកម្មបណ្តុះបណ្តាលរបស់អង្គការ

ឆ្លើយតបទៅនឹងគោលដៅនៃការបង្កើតអង្គការ សកម្មភាពបណ្តុះបណ្តាលដល់និស្សិត បុគ្គលិកអង្គការស្ថាប័ន គឺជាបេសកកម្មជាអាទិភាពទីមួយដែលត្រូវបានចាប់ផ្តើមជាបន្តបន្ទាប់នៅក្រោយពីអង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍បានទទួលការអនុញ្ញាតិជាផ្លូវការដោយក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០៥ ។ នៅក្នុងរយៈពេលឆ្នាំទីមួយ នៃការចាប់ផ្តើមបំពេញបេសកកម្មរបស់ខ្លួន អង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ បានជ្រើសរើសយកប្រធានបទសំខាន់៧ដែលពាក់ព័ន្ធដោយផ្ទាល់នៅក្នុងការងារអភិវឌ្ឍន៍សហគមន៍ អភិរក្សធនធានធម្មជាតិ និងបរិស្ថាន មកធ្វើការបណ្តុះបណ្តាលដល់និស្សិត និងបុគ្គលិកអង្គការ ។ វគ្គបណ្តុះបណ្តាលទាំងនោះ គឺ :

១. វគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន

២. វគ្គបណ្តុះបណ្តាលស្តីពីជំនាញសំរបសំរួល

៣. វគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងគំរោង

៤. វគ្គបណ្តុះបណ្តាលស្តីពីការងារអភិវឌ្ឍន៍សហគមន៍

វគ្គបណ្តុះបណ្តាលសំខាន់៧ទាំងនេះ បានផ្តួចផ្តើមរៀបចំឡើងតាមរយៈការប្រឹងប្រែងពីស្ថាបនិករបស់អង្គការ ដែលមានសិក្ខាកាមជានិស្សិតនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម សាកលវិទ្យាល័យភូមិន្ទភ្នំពេញ សាកលវិទ្យាល័យវេទមហាឫស្សី សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សាកលវិទ្យាល័យជាតិគ្រប់គ្រង សាលាកសិកម្មជាតិព្រែកលាប សាកលវិទ្យាល័យន័រតុន និងសាកលវិទ្យាល័យនានា បុគ្គលិកអង្គការស្ថាប័នមួយចំនួនទៀតក្នុងព្រះរាជាណាចក្រកម្ពុជា ដែលសរុបមានសិក្ខាកាមចំនួន ៧០នាក់ ( ស្រី ២០) ។

វគ្គបណ្តុះបណ្តាលទាំងនេះអាចដំណើរការបាន ដោយមានការលះបង់ខ្ពស់ និងចូលរួមយ៉ាងសកម្មប្រកបដោយមនសិការថ្លៃថ្លា ក្នុងការចែករំលែកចំណេះដឹង បទពិសោធន៍ ដោយដើរតួជាអ្នកសំរបសំរួល (គ្រូបណ្តុះបណ្តាល) នៅក្នុងបណ្តាវគ្គទាំងអស់ខាងលើ ។ អ្នកសំរបសំរួល ដែលបានលះបង់ពេលវេលា កំលាំងកាយ កំលាំងប្រាជ្ញា ដោយមិនគិតពីផលប្រយោជន៍ផ្ទាល់ខ្លួន នៅក្នុងការរួមចំណែកជាមួយអង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ ក្នុងគោលដៅបង្កើនសមត្ថភាពនិស្សិត យុវវ័យអោយមានលទ្ធភាពគ្រប់គ្រាន់សំរាប់ចូលរួមអភិវឌ្ឍន៍សង្គមជាតិប្រកបដោយប្រសិទ្ធិភាព រួមមាន :

១. លោក ព្រំ ង៉ា ប្រធានអង្គការ **HEKS**

២. អ្នកស្រី លុយ រស្មី នាយិការរងអង្គការ **CEPA**

៣. លោក អៀច ធា មន្ត្រីអង្គការស្បៀងអាហារពិភពលោក

៤. លោក យី គឹមថាន មន្ត្រីអង្គការ **CEDAC**

៥. លោក មៀច ផល្លា មន្ត្រីរបស់អង្គការ **CelAgrid**

៦. លោក អៀ ចុង ទីប្រឹក្សាគំរោងភាពជាដៃគូដើម្បីអភិបាលកិច្ចមូលដ្ឋាន របស់អង្គការ **UNDP**

៧. លោក ស៊ុន វិសាល មន្ត្រីរបស់អង្គការ **WCS**

៨. កញ្ញា ឃៀង សុខឡេង បុគ្គលិករបស់ អង្គការ **Heifer International**

៩. លោក លី សុភា បុគ្គលិករបស់អង្គការ **Oxfam UK**

ការចូលរួមរបស់លោក លោកស្រី កញ្ញាទាំងអស់ខាងលើនេះ ពិតជាមានតំលៃមិនអាចកាត់ថ្លៃបាន ដែលជំរុញអោយការបណ្តុះបណ្តាលអភិវឌ្ឍន៏ធនធានមនុស្ស ជាពិសេសដល់និស្សិត និងយុវវ័យអោយទទួលបានចំណេះដឹង វិជ្ជាជីវៈក្នុងការអភិវឌ្ឍន៏សហគមន៏ ប្រកបដោយលទ្ធផលល្អប្រសើរ។ វត្តមាននៃអ្នកសំរបសំរួលទាំងអស់ខាងលើ បានធ្វើអោយនិស្សិត បុគ្គលិកអង្គការ ស្ថាប័នសរុបចំនួន ៧0នាក់ ទទួលបានចំណេះដឹងថ្មី បទពិសោធន៏ថ្មី និងមានឱកាសទទួលបានការងារ និងកែលំអការងារអោយមានលក្ខណៈល្អប្រសើរ។ តាមរយៈការលះបង់ពេលវេលាចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលនេះរបស់អ្នកសំរបសំរួល ធ្វើអោយនិស្សិតដែលកំពុងសិក្សានៅតាមមហាវិទ្យាល័យនានា មានសេចក្តីសង្ឃឹមនៅក្នុងការកសាងអនាគតរបស់ខ្លួនដោយមានភាពងាយស្រួល និងមានគុណភាព ដែលអាចប្រើប្រាស់បានសំរាប់ការបំពេញការងារជាមួយមជ្ឍដ្ឋានផ្សេងៗ។ អង្គការសកម្មភាព ដើម្បស្រាវជ្រាវ និងអភិវឌ្ឍន៏ នឹងកត់ត្រាទុកជាកំណត់ហេតុពិសេសដែលមិនអាចកាត់ថ្លៃបាន នូវគំរូមនសិការដ៏ប្រសើរថ្លៃថ្លារបស់អ្នកសំរបសំរួលទាំងអស់នេះ ។

## III. គោលបំណងការបង្កើតក្រុមបណ្តុះបណ្តាលដើម្បីអនាគតមានការអភិវឌ្ឍន៍

ដូចដែលបានបញ្ជាក់នៅក្នុងប្រវត្តិបេសកកម្មបណ្តុះបណ្តាលខាងលើ អង្គការសកម្មភាព ដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៏មានគំនិតផ្តួចផ្តើមបង្កើតនូវក្រុមបណ្តុះបណ្តាលមួយដើម្បីផ្តល់ជូននូវឱកាសដល់បុគ្គលិករបស់អង្គការ ស្ថាប័ននានាដែលមានបទពិសោធន៏ការងារ ហើយដែលមានបំណងចែករំលែកចំណេះដឹងទាំងនេះដល់និស្សិត យុវវ័យជំនាន់ក្រោយសំដៅចូលរួមចំណែកក្នុងការបណ្តុះបណ្តាលធនធានមនុស្ស និងអភិវឌ្ឍន៏សង្គមកម្ពុជា ហើយដែលបេសកកម្មប្រកបដោយឧត្តមគតិមនសិការជួយគ្នាទៅវិញទៅមកនេះ នឹងមិនបង្កការរំខានពេលវេលា និងការងារបច្ចុប្បន្នរបស់ខ្លួនឡើយ ។ ក្រុមបណ្តុះបណ្តាល ដែលបង្កើតឡើងនេះនឹងមានឈ្មោះថា ក្រុមបណ្តុះបណ្តាលដើម្បីអនាគតមានការអភិវឌ្ឍន៏ **Trainer Team for Futrue Development (TTFD)** ។

មន្ត្រី បុគ្គលិកតាមបណ្តាអង្គការ ស្ថាប័ននានា ត្រូវបានទទួលស្វាគមន៏អោយចូលរួមនៅក្នុងក្រុម **TTFD** ប្រសិនបើមានការចាប់អារម្មណ៏ចង់ចែករំលែកចំណេះដឹង បទពិសោធន៏ និងជាពិសេសដើម្បីអោយខ្លួនស្ថិតនៅក្នុងផ្នែកមួយដែលចូលរួមដោយផ្ទាល់នូវការបណ្តុះបណ្តាលធនធានមនុស្ស និងជាពិសេសសំរាប់សិស្ស និស្សិត ដែលគ្មាន រឺមានលទ្ធភាពដ៏តិចតួចបំផុតនៅក្នុងការទទួលបានឱកាសបំប៉នចំណេះដឹង និងបទពិសោធន៏ដោយសារតែកំរិតជីវភាពមានភាពទន់ខ្សោយ ។ រាល់ការចូលរួមនៅក្នុងក្រុម **TTFD** គឺមិនមានប៉ះពាល់ដល់ពេលវេលាការងាររបស់ខ្លួនឡើយ គឺសមាជិកក្រុមជាអ្នកចាត់ចែងពេលវេលា និងសំរេចចិត្តដោយខ្លួនឯងដើម្បីឆ្លើយតបថាមិនអាច

រឺអាចចូលរួមជាគ្រូបណ្តុះបណ្តាលនូវប្រធានបទណាមួយទៅតាមកាលបរិច្ឆេទ ដែលអង្គការនឹងផ្ញើជូនជាដំណឹងសំរាប់ការពិចារណាក្នុងការចូលរួម ។

ការបង្កើតក្រុម **TTFD** គឺជាកត្តាធានាថារាល់ការបណ្តុះបណ្តាលធនធានមនុស្ស ជាពិសេសសិស្ស និស្សិតតាមរយៈវគ្គបណ្តុះបណ្តាលដែលរៀបចំឡើងដោយ **ARD** ត្រូវបានពង្រឹង និងពង្រីកទាំងគុណភាព និងបរិមាណដោយសារមានការចូលរួមជាច្រើនពីមន្ត្រី បុគ្គលិករបស់បណ្តាអង្គការ ស្ថាប័ននានា ។ ព្រមពេលនោះទៀតសោធន៍ការបង្កើតក្រុម **TTFD** ក៏ជាកត្តាលើកទឹកចិត្តដល់បណ្តាមន្ត្រី បុគ្គលិកដែលបានចូលរួមចែករំលែកចំណេះដឹងបទពិសោធន៍នៅក្នុងការកសាងសមត្ថភាពនិស្សិត តាមរយៈការផ្តល់តំលៃមួយជាគ្រូបណ្តុះបណ្តាលដែលអាចនឹងផ្តល់ជាកិត្តិយស និងទទួលស្គាល់ពីមជ្ឈដ្ឋាននានានូវសមត្ថភាពជំនាញ និងការសំរបសំរួលរបស់ខ្លួន ។

## IV. ការគាំទ្ររបស់អង្គការសកម្មភាព ដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ចំពោះក្រុម TTFD

អង្គការសកម្មភាព ដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ ដើរតួនាទីដ៏សំខាន់ជាអង្គការបណ្តុះបណ្តាលធនធានមនុស្ស ជាពិសេសដល់សិស្ស និស្សិត ដោយមិនគិតពីផលកំរៃ លើកលែងតែការចូលរួមជាវិភាគទានដ៏តិចតួចស្តួចស្តើងបំផុតពីសិក្ខាកាម សំរាប់ជួយសំរួលដល់ការចំណាយលើសំភារៈ និងឯកសារសំរាប់វគ្គបណ្តុះបណ្តាលក្នុងករណីដែលអង្គការមិនមានការផ្តល់ជំនួយហិរញ្ញវត្ថុពីអង្គការ ស្ថាប័នណាដើម្បីដំណើរការវគ្គនេះ ។ រាល់វគ្គបណ្តុះបណ្តាល គឺរៀបចំឡើងដោយ **ARD** ដែលការជ្រើសរើសប្រធានបទសំរាប់វគ្គ គឺជាប់ពាក់ព័ន្ធផ្ទាល់ទៅនឹងការងារអភិវឌ្ឍន៍សហគមន៍ ការងារអភិរក្សធនធានធម្មជាតិ និងបរិស្ថាន ការគ្រប់គ្រង និងអនុវត្តន៍គំរោង ដែលជាទូទៅបណ្តាអង្គការជាតិ អន្តរជាតិបាន និងកំពុងប្រើប្រាស់ចំណេះដឹង និងបទពិសោធន៍ទាំងនេះសំរាប់ជួយអភិវឌ្ឍន៍នៅក្នុងសង្គមកម្ពុជានាពេលបច្ចុប្បន្ន ។

១. នៅពេលដែលវគ្គបណ្តុះបណ្តាលត្រូវបានកំណត់ អង្គការសកម្មភាព ដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ នឹងធ្វើការទំនាក់ទំនងជាមួយគ្រប់សមាជិករបស់ក្រុម **TTFD** ដោយផ្ញើនូវកម្មវិធីបណ្តុះបណ្តាលលំអិតទៅជាមួយ ដើម្បីសមាជិកក្រុមពិនិត្យ និងពិចារណាអំពីលទ្ធភាពរបស់ខ្លួននៅក្នុងការចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលនេះ ។ សមាជិកក្រុមមានសិទ្ធិគ្រប់គ្រាន់អាស្រ័យទៅតាមពេលវេលារបស់ខ្លួន ដើម្បីសំរេចថាមិនអាចចូលរួម រឺអាចចូលរួមបានសំរាប់វគ្គបណ្តុះបណ្តាលដែលបានជូនដំណឹងនេះ ។ មានន័យថា ប្រសិនបើមិនមានពេលវេលា រឺមិនត្រូវនឹងជំនាញចំណង់ចំណូលចិត្តរបស់ខ្លួនទៅនឹងប្រធានបទណាមួយសំរាប់វគ្គនេះទេ សមាជិកក្រុមអាចសំរេចចិត្តមិនបាច់ចូលរួមក្នុងវគ្គនោះ ។

២. អង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ នឹងធ្វើការកត់ត្រាទុកនូវគ្រប់បណ្តាមន្ត្រីបុគ្គលិក ដែលបានចូលរួមនៅក្នុងក្រុម **TTFD** ដោយរួមបញ្ចូលផងដែរនូវរាល់បេសកកម្មរបស់សមាជិកក្រុមនៅក្នុងការចូលរួមបណ្តុះបណ្តាលធនធានមនុស្ស ។ អង្គការ នឹងធ្វើការទំនាក់ទំនង

ផ្លាស់ប្តូរពតិមាន ជាប់ជាប្រចាំជាមួយគ្រប់សមាជិកក្រុម **TTFD** ក្នុងគោលដៅពង្រឹង និងពង្រីក កិច្ចសហការគ្នាទៅវិញទៅមកអោយកាន់តែមានប្រសិទ្ធិភាព ។

៣. ស្របតាមបាវចនារបស់អង្គការដែលប្រកាន់យកនូវចំនុចសំខាន់៣ គឺ គុណភាព សមត្ថភាព និង តម្លាភាព អង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍នឹងរៀបចំវគ្គបណ្តុះបណ្តាលអោយ ដំណើរការប្រកបដោយគុណភាព យុត្តិធម៌ និងជោគជ័យ ដោយចាប់ផ្តើមតាំងពីការជូនដំណឹង ពីវគ្គបណ្តុះបណ្តាល ការជ្រើសរើសសិក្ខាកាម ការសំរបសំរួល និងការចាត់ចែងក្នុងដំណើរការ បណ្តុះបណ្តាល ។

៤. ជាការឆ្លើយតបទៅនឹងគុណសម្បត្តិដ៏ថ្លៃថ្លារបស់សមាជិកក្រុម **TTFD** ដែលបានលះបង់ពេល វេលា និងមានសមានចិត្តក្នុងការចែករំលែកចំណេះដឹង និងបទពិសោធន៍របស់ខ្លួន អង្គការ សកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍ជាអ្នករៀបចំនូវលិខិតទទួលស្គាល់ និងថ្លែងអំណរគុណ ដល់សមាជិកក្រុម**TTFD** ។ ពិសេសជាងនេះ ប្រសិនបើមានការចាប់អារម្មណ៍ រឺសំណូមពរពី សមាជិកក្រុម អង្គការសកម្មភាពដើម្បីស្រាវជ្រាវ និងអភិវឌ្ឍន៍នឹងរៀបចំ និងផ្តល់ជូននូវប័ណ្ណ សំគាល់សមាជិកក្រុម, នាមប័ណ្ណសមាជិកក្រុម, លិខិតបញ្ជាក់ពីគុណសម្បត្តិ ។

## V. ទិសស្លោករបស់ក្រុមបណ្តុះបណ្តាល ដើម្បីអនាគតមានការអភិវឌ្ឍន៍ TTFD

- យើងរួមគ្នាចែករំលែកចំណេះដឹង បទពិសោធន៍ទៅតាមលទ្ធភាពរបស់យើង
- យើងមានការរីករាយ និងមោទនភាពដែលបានចែករំលែកចំណេះដឹង និងបទពិសោធន៍របស់យើង
- ចំណេះដឹង និងបទពិសោធន៍ គឺជាទុនដ៏ចាំបាច់ខានមិនបានដើម្បីធ្វើអោយអនាគតមានការអភិវឌ្ឍន៍ ។